ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៩ អ.ក
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ ១៩៦ ស.ស
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ១០៨ ជ.រ
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ ០៦៦ ថ
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការ | ៖ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ និងថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៣។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ០១ ម៉ោង ០៩ ព្រឹក។ |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ០៥ ម៉ោង ១០ ព្រឹក។ |

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

ឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៦៧ (អាយុ ៥៤ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីកន្លែងកំណើត [redacted] ខេត្តកណ្ដាល។

ទីលំនៅផ្ទះ [redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] សាយ (រ) ម្ដាយឈ្មោះ [redacted] សឿន (រ) ប្រពន្ធឈ្មោះ [redacted] សុខឃឿន មានកូន ០២ នាក់។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។

ត្រូវជាប់ចោទពីបទ បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។



Scanned with CamScanner

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យបន្ទប់លេខ ១-E៦ នៃអគារ Icon លេខ ២១៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ខ. អំពីអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ស៊ីថាន ភេទស្រី កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៨ (អាយុ ៤៣ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីកន្លែងកំណើត [redacted] ខេត្តបាត់ដំបង។

ទីលំនៅភូមិព្រែកហូរកើត១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] យ៉ាវ (វ) ម្ដាយឈ្មោះ [redacted] ស៊ាន (វ) ប្ដីឈ្មោះ ប៊ីតណូវ៉ា ហេនដ្រិត ចាក់កូប មានកូន ០២ នាក់។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យនៅបុរីដឹបម៉ុងលេនម៉ាក់២៧១ (Land Mark 271) ផ្ទះលេខ ១៣៧ ផ្លូវខមមើលសល (COMMERCIAL) សង្កាត់ចាក់អង្រែលើ ខណ្ឌចាំការមន រាជធានីភ្នំពេញ។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យនៅជាន់ទី១ អគារលេខ ៧បេ ផ្លូវលេខ៥១ កែងផ្លូវលេខ១០៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យអគារលេខ១៥ ផ្លូវលេខ ២៥៣ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សំណុំរឿងព្រហ្មទណ្ឌនេះ** បញ្ជូនមកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ០៣០ ដក ដស/២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមាន៖

**អង្គហេតុដែលប្តឹងមកតុលាការ**

កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១០ នាទីព្រឹក ឈ្មោះ [redacted] **NORA HENDRIK JACOBS (ប៊ីតណូវ៉ា ហេនដ្រិត ចាក់កូប)** ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ជាតិបែលហ្ស៊ិច បានធ្វើដំណើរចេញពីផ្ទះ ដោយបើកបរម៉ូតូ១គ្រឿងម៉ាក PCX ពណ៌ក្រហម ពាក់ស្លាកលេខ កណ្តាល 1AE-9328 (ទិសដៅពីត្បូងទៅជើង) លុះមកដល់ចំណុចលើផ្លូវបេតុង ស្ថិតនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ត្រូវបានរថយន្តដឹកដី (ឌុមធំ) ០១ គ្រឿង ម៉ាក នីសាន់ ពណ៌ខៀវ គ្មានស្លាកលេខ បើកបរដោយឈ្មោះ [redacted] **សំណាង ហៅ [redacted] សំណាង** ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ (ទិសដៅពីត្បូងទៅជើង) បើកបរមកបុក និងកៀជនរងគ្រោះពីក្រោយ ធ្វើឱ្យខ្ទាតម៉ូតូទៅខាងស្ដាំ ហើយជនរងគ្រោះក៏ធ្លាក់ចូលទៅក្រោមកង់រថយន្តដឹកដី



Scanned with CamScanner

ខាងលើនោះ បណ្តាលឱ្យកិនជនរងគ្រោះរងរបួសស្នាមជាទម្ងន់។ បន្ទាប់មកជនបង្ករឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង បានបើកបររថយន្តគេចពីកន្លែងកើតហេតុបាត់ ចំណែកជនរងគ្រោះត្រូវបានក្រុមគ្រួសារបញ្ជូនទៅព្យាបាលរបួសនៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ និងបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យបាកកក ប្រទេសថៃ ប៉ុន្តែដោយស្ថានភាពរបួសជនរងគ្រោះធ្ងន់ធ្ងរ ក៏បានបណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិតនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ តែម្តង។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

### ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី

អំពីវិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

### ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

**សវនាការលើកទី១ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក**

**១. ការសួរចម្លើយជនជាប់ចោទ**

១.១. ចម្លើយជនជាប់ចោទឈ្មោះ [redacted] សំណាង នៅចំពោះមុខតំណាងអយ្យការ៖ ចំពោះបណ្តឹងរបស់ឈ្មោះ [redacted] ស៊ីថាន ប្តឹងខ្ញុំថា បានបើកបរបង្កគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យប្តីគាត់ស្លាប់នោះ ខ្ញុំសូមបដិសេធមិនទទួលស្គាល់នោះទេ។ នៅថ្ងៃកើតហេតុ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ខ្ញុំបើកឡានដឹកដី ០១ គ្រឿងម៉ាក នីសាន់ ពណ៌ខៀវ អត់ពន្ធ គ្មានស្លាកលេខ ទម្ងន់ ០៨ តោន មកពីចាក់ដីវិញ ទិសដៅពីត្បូងទៅជើង មកដល់ត្រង់ចំណុចផ្លូវបេតុងមួយកន្លែង ស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ខណៈពេលខ្ញុំកំពុងបើកបរឡានសុខៗ ស្រាប់តែលឺសូរផាំងពេលនោះខ្ញុំឈប់ឡាន រួចចុះទៅមើល ឃើញម៉ូតូ០១ គ្រឿងមិនចាំម៉ាក ពណ៌ក្រហម ទូលក់កាហ្វេ និងឃើញជនរងគ្រោះជនបរទេសជាអ្នកបើកបរម៉ូតូ ឃើញដូច្នេះខ្ញុំបានទៅជួយគ្រា និងដោះមួកសុវត្ថិភាពគាត់ចេញ ហើយជនរងគ្រោះបានហាមាត់តិចៗ តែខ្ញុំស្តាប់ភាសាគាត់មិនបាន ខ្ញុំក៏បន្តបើកឡានទៅដឹកដីជាធម្មតាវិញ។ ខ្ញុំមិនដឹងថា ជនរងគ្រោះរងគ្រោះថ្នាក់មកពីអ្វីនោះទេ ព្រោះក្នុងពេលកើតហេតុ ខ្ញុំបើកបរឡានសុខៗ ស្រាប់តែឮសម្លេងប្រាវ ខ្ញុំក៏បានឈប់ឡានប្រហែល ១០ ម៉ែត្រ ពីកន្លែងកើតហេតុ រួចក៏ចុះទៅមើល តែខ្ញុំមិនបានសួរនាំអ្នកនៅម្តុំនោះថា ជនរងគ្រោះរងគ្រោះថ្នាក់មកពីអ្វីទេ។ អ្នកដែលនៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ខាងលើនោះ ខ្ញុំស្គាល់ម្នាក់គាត់ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស អាយុ ៤០ ឆ្នាំ មុខរបរ ជាងឡាន មានទីលំនៅភូមិព្រែកហូរកើត១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល។

**២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

២.១. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីថាន៖ ខ្ញុំត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] NORA HENDRIK JACOBS (ន័រណ្ឌារ៉ា ហេនឌ្រីត ចាក់កូប)។ ថ្ងៃកើតហេតុ ខ្ញុំមិនបាននៅផ្ទះទេគឺ ខ្ញុំនៅបាត់ដំបង ដោយកូនខ្ញុំប្រាប់ថា "ប៉ាជួបគ្រោះថ្នាក់ចរាចរណ៍" ហើយមួយសន្ទុះក្រោយមកមានគេទូរស័ព្ទប្រាប់ថា "ប្តីខ្ញុំត្រូវឡានដឹកដីបុក"។ ថ្ងៃកើតហេតុគឺនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១។ ក្រោយពេលខ្ញុំឡើងមក ខ្ញុំដឹងថាប្តីខ្ញុំ នៅរ៉ូយ៉ា



Scanned with CamScanner

លំភ្នំពេញ ដើម្បីសង្គ្រោះក្រោយមកដឹកទៅសង្គ្រោះនៅថៃ បន្តក្រោយគេឯភ្នំពេញបាន ០២ យប់ ហើយក៏បញ្ជូនទៅថៃ ០២ សប្តាហ៍។ លិខិតបញ្ជាក់របស់ពេទ្យប្រាប់ថា បាក់ឆ្អឹងជំនីរ ប្លោកនោម ដោយពេទ្យប្រាប់ថា មានរបស់ធ្ងន់សង្កត់ពីលើ។ ពេលខ្ញុំត្រឡប់មកវិញ គឺអ្នកភូមិប្រាប់ខ្ញុំថា ឡានដឹកដីជាអ្នកបុកប្តីខ្ញុំ។ ចំពោះចំនួនឡានដឹកដីដឹងថា មានចំនួន ០២។ ចំពោះឡានបុក មិនដឹងថា មានស្លាកលេខប៉ុន្មានទេ។ អ្នកភូមិគ្រាន់តែបញ្ជាក់ថា ម្ចាស់ឡានដឹកដីគឺកូនមេភូមិហ្នឹង។ ក្រោយកើតហេតុ ខ្ញុំមិនបានសាកសួរផ្ទាល់នៅកន្លែងកើតហេតុទេ គឺខ្ញុំពឹងឱ្យបងប្អូនជួយសួរ តែអ្នកភូមិគ្រាន់តែប្រាប់ថា ពួកគាត់មិនហ៊ានធ្វើសាក្សីទេ ដោយសារពួកខ្ញុំរស់នៅក្នុងភូមិហេតុនេះមិនហ៊ានធ្វើសាក្សីឡើយ។ ក្រៅពីអ្នកដឹងពត៌មាន គឺមានតែអ្នកសង្គ្រោះប្តីខ្ញុំ។ អ្នកដែលជួយសង្គ្រោះប្តីខ្ញុំ កូនគាត់ជាអ្នករស់នៅទីនោះប្រាប់ថា "ពូបារាំងត្រូវឡានបុក"។ ចំពោះសាក្សី ខ្ញុំបានបញ្ចូលមា នឈ្មោះ [redacted] ស្រីហៀក ឈ្មោះ [redacted] ស្រីហ៊ិន និងឈ្មោះ[redacted]សុខវ័ន្ត។ នៅកន្លែងកើតហេតុមានកាម៉េរ៉ាសុវត្ថិភាព ហើយក៏មានវីដេអូដែលគេថតបានដែរ តែគេមិនឱ្យ។ ចំពោះពាក្យបណ្តឹង គឺខ្ញុំត្រឡប់មកពីថៃទើបដាក់។ ក្រោយពីខ្ញុំត្រឡប់មកពីថៃ ខ្ញុំចុះទៅកន្លែងកើតហេតុ ហើយសួរនាំអ្នកលក់បន្លែ ម្តងគាត់ថា ឡានតូចបុក ម្តងថា ឡានធំបុក ហើយគាត់ឆ្លើយថា មិនដឹង គាត់មិនចង់ឆ្លើយ។ ក្រោយកើតហេតុ ០១ ខែ ទើបខ្ញុំត្រឡប់មកវិញ ហើយអ្នកនៅកន្លែងកើតហេតុថា ឡានបុក។ ចំពោះផ្ទះរបស់អ្នកឃើញហេតុប្រាប់ថា ឡានបុក គឺឡានដឹកដី ឡានគ្មានស្លាកលេខ ដោយអ្នកស្រុកប្រាប់ថា កូនមេភូមិ។ នៅពេលកើតហេតុភ្លាម គឺឡានពេទ្យមកហើយគេលើកប្តីខ្ញុំដាក់ឡានពេទ្យ។ នេះតាមការបញ្ជាក់របស់កូនរបស់ខ្ញុំ។ ពេលសង្គ្រោះប្តីខ្ញុំ អ្នកលក់បន្លែប្រាប់ថា គាត់ជាអ្នកលើកម៉ូតូប្តីខ្ញុំ។ ចំពោះអ្នកប្រាប់ថា "កូនមេភូមិបុក" គឺអ្នកភូមិនិយាយតៗគ្នា។ ប្តីខ្ញុំ និងខ្ញុំក៏បានចុះសំបុត្រអាពាហ៍ពិពាហ៍ គឺចុះនៅស្រុកមោង។ ខ្ញុំសូមបញ្ជាក់ថា អ្នកដែលឃើញហេតុការណ៍ផ្ទាល់ គឺកូនរបស់អ្នកជួយគ្រួសារខ្ញុំពេលគាត់មកទិញនំ ដោយប្រាប់ថា "ពូបារាំងឡានបុក"។ ក្មេងនោះមានអាយុ ០៥ ឆ្នាំ ប៉ុណ្ណោះ ដោយសារគាត់មានអាយុតូចពេក។ ចំពោះអ្នកប្រាប់ថា "ឡានដែលបុកប្តីខ្ញុំ គឺឡានកូនមេភូមិ។ ចំពោះអ្នកភូមិដែលប្រាប់ខ្ញុំនោះថា "សុំទោសគាត់មិនហ៊ាននិយាយ ព្រោះគាត់រស់នៅភូមិហ្នឹង"។ ដោយអ្នកភូមិប្រាប់ថា ប្រសិនបើត្រូវការឯកសារអ្វីខ្លាចមេភូមិមិនបញ្ជាក់ឱ្យ។ ខ្ញុំដឹងថា កូនមេភូមិដែលកូនមេភូមិមាន ០២ ហើយកូនមេភូមិដែលទើបឡើងថ្មី គឺមេភូមិថ្មីនេះតែម្តង ដែលមានឈ្មោះ សយ សំណាង។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានលឺថា មេប៉ុស្តិ៍អ្នកឱ្យឡានដឹកដី នោះបើកចេញទៅក្រោយកើតហេតុ។ ខ្ញុំសំណូមពរតុលាការទាមទារយុត្តិធម៌ និងសំណងជម្ងឺចិត្តចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

**៣. ការស្តាប់ចម្លើយសាក្សី**

**៣.១.** សាក្សីឈ្មោះ[redacted] សឿន៖ បច្ចុប្បន្នខ្ញុំជាមេភូមិព្រែកហូរកើត ១ និងជាម្តាយរបស់ឈ្មោះ [redacted] សំណាង។ ខ្ញុំជាមេភូមិតាំងពីឆ្នាំ២០១៣។ ក្នុងភូមិព្រែកហូរ មានចំនួន ០៦ ភូមិ មានភូមិព្រែកហូរកើត ព្រែកហូរកើត១ ព្រែកហូរលិច ព្រែកហូរលិច១ ភូមិបត្តាជី និងភូមិបត្តាជី១។ ចំពោះការចោទប្រកាន់ថា កូនខ្ញុំបុក ជនរងគ្រោះគឺមិនពិតទេ។ ចំពោះរឿងហេតុនេះពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ គឺខ្ញុំមិននៅកន្លែងកើតហេតុទេ ក្រោយកើតហេតុបានចំនួន ១០ នាទី ទើបខ្ញុំមកដល់កន្លែងកើតហេតុ ខ្ញុំជិះទិសដីពីផ្ទះទៅសង្កាត់។ ពេលមក ដល់កន្លែងកើតហេតុខ្ញុំបានឃើញកូនប្រុសខ្ញុំឈ្មោះ [redacted]សំណាង និងឡានរបស់កូនប្រុសខ្ញុំឈប់ឡាន នៅខាងមុខ ចុះអ្នក



Scanned with CamScanner

ជួយជនរងគ្រោះនៅក្រោយ។ ពេលទៅដល់កន្លែងកើតហេតុខ្ញុំបានឃើញឡានរបស់កូនប្រុស ខ្ញុំ។ ក្រៅពីកូនប្រុសខ្ញុំ មានប៉ូលីសឈ្មោះ [redacted] ចាន់ភ័ក្ត់ ជាមេប៉ុស្តិ៍ព្រែកហូរ ក្រៅពីកូនប្រុស និងប៉ូលីស ខ្ញុំដឹងថាមានមនុស្សច្រើននាក់ទៀត តែខ្ញុំចាំមិនអស់។ ដោយខ្ញុំឃើញកូនប្រុសខ្ញុំរឹតទ្រូងមនុស្សដែលជាជនរងគ្រោះ ដោយឃើញមានមនុស្សនាំគ្នាលើកក្នុងនោះក៏មានកូនប្រុសខ្ញុំជួយលើកជនរងគ្រោះដែរដោយដឹងថា ជនរងគ្រោះជិះម៉ូតូចាប់ហ្វ្រាំងហើយបោកផ្ងួល នេះជាការបញ្ជាក់ពីកូនប្រុសខ្ញុំ។ ពេលជួយនោះគឺគេរំកិលជនរងគ្រោះចេញពីផ្លូវ។ ពេលនោះខ្ញុំក៏មិនដឹងថាមានឡានពេទ្យមកឬអត់។ ហើយមានម្នាក់ឱ្យហៅប្រពន្ធ និងគ្រួសាររបស់ជនរងគ្រោះមក។ អ្នកដែលនាំជនរងគ្រោះទៅពេទ្យគឺឈ្មោះ សុង និងជាអ្នកធ្វើការនៅកន្លែងបារាំង។ ដោយឱ្យឈ្មោះ សុង នាំទៅពេទ្យគេនាំគ្នាហៅឈ្មោះ សុង ពីផ្ទះគាត់មក។ ក្រោយមកគឺឈ្មោះ [redacted] ចាន់ភ័ក្ត់ ជាអ្នកហៅឡានពេទ្យមក។ នៅតាមផ្លូវនោះគឺផ្លូវតូច ០៦ ម៉ែត្រ មានផ្ទះអ្នកភូមិសងខាង ហើយមិនមានកាមេរ៉ាទេ ប្រជាពលរដ្ឋដែលនៅទល់មុខកន្លែងកើតហេតុខ្ញុំក៏ស្គាល់តែខ្ញុំមិនស្គាល់ឈ្មោះអ្វីនោះទេ ដោយសារតែពួកគាត់ ទើបមកនៅ។ ចំពោះកន្លែងកើតហេតុគឺមិនស្ថិតនៅក្នុងភូមិរបស់ខ្ញុំទេ។ មេភូមិដែលស្ថិតនៅកន្លែងកើតហេតុ ឈ្មោះ [redacted] ណា ដោយគាត់ឡើងជាមេភូមិនៅឆ្នាំ១៩៨០ ជាង ឈ្មោះ [redacted] ណា អាយុជាង ៦០ ឆ្នាំហើយគាត់រស់នៅផ្ទះគ្មានលេខ។ មូលហេតុដែលខ្ញុំទៅកន្លែងកើតហេតុដោយសារតែពេលនោះខ្ញុំជិះកង់ទៅចែវន្យ ដោយកូនខ្ញុំមិនបានគេហៅខ្ញុំទេ។ ឡានរបស់កូនប្រុសខ្ញុំគឺខាងស្តាំឈប់នៅខាងស្តាំ ជនរងគ្រោះនៅខាងលិច។ ពេលទៅដល់កន្លែងកើតហេតុឃើញឡាននៅខាងស្តាំ ម៉ូតូនៅខាងក្រោយឡាន ចម្ងាយពីឡានទៅម៉ូតូប្រហែល ០៥ ទៅ ០៦ ម៉ែត្រ ជាចម្ងាយប៉ាន់ស្មាន។ នៅកន្លែងកើតហេតុផ្ទះប្រជាពលរដ្ឋ ដែលស្ថិតនៅសងខាង ខ្ញុំមិនស្គាល់ទេ។ ក្រៅពីឈ្មោះ [redacted] ហ៊័រ ដោយសារតែភូមិខុសគ្នា ខ្ញុំមិនស្គាល់ទេ។ ខ្ញុំបានឃើញស្នាមកង់ម៉ូតូ ពីខាងត្បូងទៅជើង ប្រហែល ០៥ ទៅ ០៦ ម៉ែត្រ ដែលខ្ញុំឃើញថាជាស្នាមកង់ម៉ូតូចាប់ហ្វ្រាំងអូសប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ចាន់ភ័ក្ត់ ជាប៉ូលីសប៉ុស្តិ៍ព្រែកហូរ មិនជាប់សាច់ឈាមទេ ឈ្មោះ [redacted] ហ៊័រ ក៏មិនមែនសាច់ ឈាមដែរ។ ឈ្មោះ [redacted] សុខវន្ត ប្រាប់ថា គ្រោះថ្នាក់គឺឈ្មោះ [redacted] សុខហ៊័រ ប្រាប់ថា មិនមែនបុកទេ។ ខ្ញុំសូមបញ្ជាក់ថា កន្លែងកើតហេតុនៅព្រែកហូរកើត ខ្ញុំជាមេភូមិព្រែកហូរកើត១។ ចំពោះមេភូមិព្រែកហូរកើត គឺផ្សេងទៀត។ ពេលមានគ្រោះថ្នាក់ចរាចរណ៍ខ្ញុំជិះកង់ឆ្លងកាត់ទើបឃើញ ហើយបានឃើញចែវន្យទេ។ ឈ្មោះ [redacted] ជេ គឺប្រជាជនរស់នៅតំបន់នោះតែខ្ញុំលឺតែគេហៅគាត់ថា [redacted] ជេ គឺមុខផ្ទះឈ្មោះ [redacted] ជេ។

**សវនាការកលើកទី២ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក**

**១. ការស្តាប់ចម្លើយសាក្សី**

១.១. សាក្សីឈ្មោះ [redacted] ស្រីហៀក៖ នៅថ្ងៃកើតហេតុ ខ្ញុំជិះម៉ូតូពីខាងជើងមកផ្សារជាមួយបងស្រី ដោយឃើញជនរងគ្រោះដេកស្តូកស្តឹងនៅផ្លូវ ដោយឃើញថា តាបារាំងត្រូវដេកនៅផ្លូវ ហើយឃើញឡានរបស់ឈ្មោះ [redacted] សំណាង នៅពីមុខ។ ខ្ញុំមកដល់ពេលកើតហេតុហើយ ដោយពេលនោះខ្ញុំបានឃើញរឿងហេតុកើតឡើងហើយ។ ជនរងគ្រោះហូរឈាមត្រង់ត្រគាក ដោយគេនាំគ្នាចូលលើកគាត់ ដោយឈ្មោះ [redacted] សំណាង និងប្រពន្ធគាត់ចូលទៅលើកជនរងគ្រោះ។ ម៉ូតូរបស់ជនរងគ្រោះត្រឡប់ត្រឡិន បែរក្បាលទៅខាងលិច ដោយម៉ូតូនោះមានសភាពខ្ទាត់ចេញ ខ្ញុំយល់ថា គ្រោះថ្នាក់ចរាចរណ៍ តែមិនមែនជិះទៅបុកដើមឈើ និងបង្គោលភ្លើងទេ។



Scanned with CamScanner

កូឡាត់ទៅខាងកៀន មនុស្សនៅកណ្ដាលផ្លូវ។ សភាពជនរងគ្រោះហូរឈាមតាមត្រចៀក ខោអាវគាត់សុទ្ធតែ ដី ហូរឈាមត្រង់ត្រចៀក ខ្ញុំឃើញហូរឈាមផ្នែកខាងក្រោយខ្នង តែមិនមានបែកក្បាល។ ពេលលើកគាត់ឡើង ជន រងគ្រោះសន្លប់បាត់ហើយក៏នាំគ្នាលើកយកមកខ្លាចគាត់ក្ដៅ។ នៅកន្លែងកើតហេតុមានតែឡានឈ្មោះ [redacted] សំណាង មិនមានឡានផ្សេងទៀតទេ ឡាននោះពុំមានផ្ទាកដីទេ ពុំមានស្លាកលេខដែរ។ ខ្ញុំសូមបញ្ជាក់ថា ពេលខ្ញុំទៅ ដល់ឈរមើលឃើញជនរងគ្រោះទើបឃើញឈ្មោះ [redacted] សំណាង និងប្រពន្ធចុះមក។ ស្រាប់តែមានប៉ូលីសជិះ កាត់ស្ទះចរាចរណ៍ ប៉ូលីសក៏សួរឈ្មោះ [redacted] សំណាង ថា "មានរឿងអី" ទើបឈ្មោះ [redacted] សំណាង ថា "មិន ដឹងដែរ ពេលបើកឡានសុខៗស្រាប់តែលឺសូរផ្ទុស"។ ខ្ញុំស្គាល់ឈ្មោះ [redacted] សំណាង ដោយសារតែជាអ្នកភូមិ ជាមួយគ្នា តែខ្ញុំមិនដឹងថាគាត់បើកឡានលឿនឬអត់ទេ។ ពេលខ្ញុំមកដល់កន្លែងកើតហេតុ ទល់មុខកន្លែងកើត ហេតុប្រាប់ថា "ឡានដឹកដីកិនគាត់"។ ឯអ្នកផ្សេងនិយាយថា "កុំចេះតែថាឡានកិន" អ្នកនិយាយនោះជាបងប្អូន ឈ្មោះ [redacted] សំណាង។ ចំណែកឈ្មោះ [redacted] ស្រីហ៊ិន ជាបងស្រីខ្ញុំ។

១.២. អំណានចម្លើយចម្លើយសាក្សីឈ្មោះ [redacted] សុខហ័រ ហៅ ទ្រាម៉ៅ៖ ខ្ញុំពុំមានជាប់សាច់ឈាមជាមួយ ឈ្មោះ [redacted] សំណាង នោះទេ ហើយខ្ញុំក៏ធ្លាប់មានទំនាស់អ្វីជាមួយឈ្មោះ [redacted] ស៊ីថាន នោះទេ តែខ្ញុំស្គាល់ ឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ស៊ីថាន ព្រមទាំងប្ដីជនរងគ្រោះ ពីព្រោះពួកគាត់ជាអ្នករស់នៅក្នុងភូមិឃុំ ជាខ្ញុំដែរ។ កាលពីថ្ងៃទីខែមិនចាំ ឆ្នាំ២០២១ មិនបានមើលម៉ោង នៅពេលបាយថ្ងៃហើយ ខ្ញុំកំពុងអង្គុយចុចទូរស័ព្ទ នៅក្នុងបន្ទប់ ស្រាប់តែឮសំឡេងអូសប្រាំងម៉ូតូ និងឮសូរផាំង ពេលនោះខ្ញុំរត់ចេញពីបន្ទប់មកមើលឃើញបុរស ជនជាតិម្នាក់ ស្គាល់មុខ តែមិនស្គាល់ឈ្មោះ ដេកដួលនៅលើផ្លូវបេតុងមុខម៉ាត ២៥០០ ទល់មុខផ្ទះខ្ញុំ ឃើញដូច្នេះ ខ្ញុំក៏រត់ទៅជួយលើកជនរងគ្រោះនោះ ហើយក៏មានអ្នកដំណើរតាមផ្លូវម្នាក់ និងម្ចាស់ឡានដឹកដីឈ្មោះ សំណាង មកជួយលើកជនរងគ្រោះផងដែរ តែលើកមិនរួច គ្រាន់តែលើកក្បាលជនរងគ្រោះដាក់សាក់កាដូឱ្យជនរងគ្រោះ កល់ក្បាលប៉ុណ្ណោះ។ នៅថ្ងៃកើតហេតុ ខ្ញុំមិនដឹងថា ករណីគ្រោះថ្នាក់ចរាចរណ៍នោះ បណ្ដាលមកពីអ្វីនោះទេ គ្រាន់តែខ្ញុំឃើញស្នាមជើងកង់ម៉ូតូជនរងគ្រោះចាប់ហ្វ្រាំងអូសប្រហែលជាជាងដប់ម៉ែត្រ។ ចំណែកជនរងគ្រោះ ដេកដួលនៅលើផ្លូវ ខ្ញុំគ្រាន់តែលើកក្បាលគាត់និងសាកកាដូរគាត់ប៉ុណ្ណោះ ពុំបានលើកចេញពីកន្លែងកើតហេតុ នោះទេ ចំណែកម៉ូតូជនរងគ្រោះដួលចម្ងាយពីជនរងគ្រោះប្រហែលជាពីរម៉ែត្រ។ នៅពេលខ្ញុំលើកជនរងគ្រោះ នោះ ខ្ញុំឃើញជនរងគ្រោះបើកភ្នែកមើលព្រឹមៗ និងឃើញដៃស្ដាំជនរងគ្រោះដាច់របួសហូរឈាម ក្រៅពីនេះខ្ញុំ មិនបានស្ទាប ឬឆែកខ្ញុំគាត់មើលថា គាត់របួសកន្លែងណាខ្លះទេ។ ក្រោយកើតហេតុ នៅពេលឡានពេទ្យទៅដល់ កន្លែងកើតហេតុ និងលើកជនរងគ្រោះដាក់លើឡានពេទ្យហើយ ទើបឃើញមានប៉ូលីសចរាចរណ៍ចុះទៅវាស់ វែងនៅកន្លែងកើតហេតុនោះ។ នៅពេលកើតហេតុ ខ្ញុំឃើញឡានដឹកដីរបស់ឈ្មោះ សំណាង បន្ទាប់មកមានឡាន តូចមួយគ្រឿងទៀត មិនចាំម៉ាក នៅមុខឡានដឹកដីនោះ និងបន្ទាប់ពីកូនឡានទៅ មានឡានដឹកកូនឈើមួយគ្រឿង ទៀត បើកនៅខាងមុខកូនឡាន ក្រៅពីនេះខ្ញុំពុំបានឃើញមានឡានអ្វីទៀតទេ។ នៅពេលនោះខ្ញុំមិនបានឮគេ និយាយថា ករណីគ្រោះថ្នាក់ចរាចរណ៍នោះបង្កឡើងយ៉ាងណានោះទេ ដោយគ្មានអ្នកណានិយាយអ្វីទាំងទេ ស្ងាត់ ទាំងអស់គ្នា។



Scanned with CamScanner

១.៣. អំណានចម្លើយសាក្សីឈ្មោះ [redacted] ស្រីហ៊ិន៖ ខ្ញុំពុំមានជាប់សាច់ញាតិជាមួយឈ្មោះ [redacted] ស៊ីថាន នោះទេ ហើយខ្ញុំក៏មិនធ្លាប់មានទំនាស់អ្វីជាមួយឈ្មោះ [redacted] សំណាង នោះទេ តែខ្ញុំស្គាល់ឈ្មោះ [redacted] ស៊ីថាន និងឈ្មោះ [redacted] សំណាង ពីព្រោះខ្ញុំជាអ្នករស់នៅភូមិឃុំជាមួយអ្នកទាំងពីរខាងលើនេះ ។ កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០២១ ជាថ្ងៃរៀបការចៅរបស់លោកប្រធានភូមិព្រែកហូរលិចឈ្មោះ ណាង នៅវេលាម៉ោង ១០ ព្រឹក ខ្ញុំ និង ប្អូនស្រីឈ្មោះ [redacted] ស្រីហៀក អាយុ ៣០ ឆ្នាំ បាននាំគ្នាជិះម៉ូតូ១គ្រឿង ម៉ាក HONDA DREAM ស៊េរី២០១៥ ពណ៌ខ្មៅ មិនចាំពាក់ស្លាកលេខ ចេញពីផ្ទះទៅទិញម្ហូបនៅផ្ទះយាយប៉ោយ ឆ្លងកាត់តាមផ្លូវបេតុងមួយកន្លែង ដល់ចំណុចផ្ទះយាយប៉ោយ ស្ថិតនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានឃើញមានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងនៅទល់មុខផ្ទះយាយប៉ោយ តែនាងខ្ញុំមិនបានឃើញហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នោះផ្ទាល់ទេ ពេលនាងខ្ញុំទៅដល់ករណីគ្រោះថ្នាក់ចរាចរណ៍នោះបានកើតឡើងរួចទៅហើយ ដោយនាងខ្ញុំឃើញជនបរទេសម្នាក់ មិនស្គាល់ឈ្មោះ ភេទប្រុស មានស្លាយសាក់កាដូពីក្រោយ ដេកផ្ងួលនៅកៀនកង់ឡានដឹកដី១គ្រឿង ទម្ងន់ ៥ តោន ពណ៌ខៀវ គ្មានស្លាក លេខ ដេកផ្ងួលក្បែរកងឡានខាងក្រោយនៅខាងលិចឡានក្បាលទៅត្បូង ហើយពេលនោះឡានដឹកដីនោះបាន បើកទៅមុខបន្តទៀតប្រហែលជា ១០ ម៉ែត្រ ទើបឈប់ ឃើញម្ចាស់ឡានដឹងដីនោះ គាត់ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុប្រហែល ៤០ ឆ្នាំ ជាកូនរបស់លោកស្រីមេភូមិព្រែកហូរកើត២ [redacted] សឿន បានចុះមកមើលនឹង លើកជនបរទេសជាជនរងគ្រោះចេញពីកន្លែងកើតហេតុ ដោយមានឈ្មោះ [redacted] សំណាង និងជាងឡានម្នាក់ ឈ្មោះ ម៉ាប់ បានលើកជនរងគ្រោះរំកិលចេញពីកន្លែងកើតហេតុ ពីព្រោះមុនដំបូងជនរងគ្រោះដេកផ្ងួលបែរ ក្បាលទៅជើង ហើយត្រូវឈ្មោះ [redacted] សំណាង និង ឈ្មោះ ម៉ាប់ បានលើករំកិលជនរងគ្រោះចេញពីកន្លែងកើតហេតុបន្តិច ដាក់ឱ្យជនរងគ្រោះដេកបែរក្បាលទៅត្បូងវិញ។ ខ្ញុំចាំថាម៉ូតូជនរងគ្រោះ មិនចាំម៉ាក ពណ៌ ក្រហម ឃើញផ្ងួលនៅខាងលិចផ្លូវ កៀនតូបកាហ្វេ។ នៅពេលខ្ញុំឈរមើលនោះ ខ្ញុំឮឈ្មោះ [redacted] សំណាង និយាយថា "គាត់បើកទ្វារ ឡានចុះមក ឮស្នូរតែភ្ញួស ដោយនាងខ្ញុំឮឈ្មោះ [redacted] សំណាង និយាយតែប៉ុណ្ណឹង។ បន្ទាប់មកនៅពេលឈ្មោះ [redacted] សំណាង កំពុងតែឈរនៅកន្លែងកើតហេតុនោះ ខ្ញុំឃើញអតីតមេប៉ុស្តិ៍ព្រែកហូរឈ្មោះ ក្រាច់ បច្ចុប្បន្នគាត់ជាមេប៉ុស្តិ៍ខ្ពបវែក បានចង្អុលប្រាប់ឱ្យអ្នកបើកឡានដឹកដីឈ្មោះ [redacted] សំណាង បើកឡានចេញទៅ ហើយឈ្មោះ [redacted] សំណាង ក៏បើកឡានចេញទៅបាត់ទៅ។នាងខ្ញុំឮអ្នកភូមិដែលឈរមើលករណីគ្រោះថ្នាក់ចរាចរណ៍នៅកន្លែងកើតហេតុនោះ ពួកគាត់និយាយថាករណីគ្រោះថ្នាក់ចរាចរណ៍ គឺបង្កឡើងរវាងឡានដឹកដី បុកគ្នាជាមួយម៉ូតូជនរងគ្រោះ ហើយនាងខ្ញុំបានឮតែប៉ុណ្ណឹង មិនដឹងថាខាងណាខុស ខាងណាត្រូវនោះទេ។ នៅកន្លែងកើតហេតុ ខ្ញុំឃើញមានតែឡានដឹកដីមួយគ្រឿងរបស់ឈ្មោះ [redacted] សំណាង ប៉ុណ្ណោះ ពុំឃើញមានឡានផ្សេងទៀតនៅពីមុខ ឬ ពីក្រោយកន្លែងកើតហេតុនោះទេ ចំណែកជនរងគ្រោះ ខ្ញុំឃើញគាត់ស្លៀកខោក្រណាត់ជើងវែង ពណ៌ខ្មៅ ពាក់អាវសាច់ក្រណាត់ដៃខ្លី ពណ៌ខៀវ ស្រដៀងពណ៌អាវខោ ប៊ិយ ហើយពេលឈ្មោះ [redacted] សំណាង និងឈ្មោះ ម៉ាប់ លើកជនរងគ្រោះ នាងខ្ញុំឃើញជនរងគ្រោះមានឈាម ហូរដូចគេអារកមាន់អញ្ចឹងចេញពីត្រចៀកគាត់ និងឃើញកែងដៃជនរងគ្រោះរលាតចេញឈាម ចំណែកកន្លែងផ្សេងទៀតនាងខ្ញុំមិនបានឃើញទេ ព្រោះគេមិនដោះខោអាវជនរងគ្រោះមើលនោះទេ។



Scanned with CamScanner

## សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

**ក. ការកត់សម្គាល់ន្លឹវរបស់៖**

១. ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីថាន៖ ខ្ញុំសុំណូមពរទាមទារសំណងជម្ងឺចិត្តចំនួន ១.០០០. ០០០ (មួយលាន) ដុល្លារអាមេរិក។

២. ជនជាប់ចោទឈ្មោះ [redacted] សំណាង៖ អវត្តមាន។

**ខ. សេចក្ដីសន្និដ្ឋាន៖**

**១. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក [redacted] សន្និដ្ឋានថា៖ ក្រោយពីបានស្ដាប់ការសាកសួរដេញដោលនាពេលសវនាការ ឃើញថាមានករណីបង្កគ្រោះថ្នាក់ចរាចរណ៍ បណ្ដាលមកពីឈ្មោះ សយ សំណាង ប្រព្រឹត្តនៅភូមិព្រែកហូរ ប្រាកដមែនតាមមាត្រា ៨២ និងមាត្រា ៨៥ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។ ក្នុងរឿងនេះរបាយការណ៍សំយោគគឺផ្ទុយនឹងខាងមន្ទីរពេទ្យមានការបញ្ជាក់ច្បាស់ សភាពសពមានរងសំពាធវត្ថុធ្ងន់ កិនលើ ប្រសិនបើដូចរបាយការណ៍របស់មន្ត្រីនគរ បាលយុត្តិធម៌មិនអាចប៉ះពាល់ដល់សួតនោះទេ ហេតុនេះពិតជាមានការបើកឡានកិនពីលើ ហើយចម្លើយសាក្សីទី១ នៅកន្លែងកើតហេតុពុំមានឡានផ្សេងទៀតែ គឺមានតែឡានរបស់ជនជាប់ចោទ ហើយការស្រែករបស់សាធារណៈជនថាឡានដឹកដីកិន។ ចម្លើយទាំងអស់នេះអាចដាក់បន្ទុកលើជនជាប់ចោទ ចំណែកសាក្សីផ្សេងជាសាក្សីរបស់ជនជាប់ចោទ មិនអាចជឿទុកចិត្តបាន។ សំណងគឺកូនក្ដីខ្ញុំបាទទាមទារចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក និងសុំផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

**២. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីជាលាយលក្ខណ៍អក្សរ៖**

**២.១. អំពីអង្គហេតុ**

កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១០ ព្រឹក ជនរងគ្រោះឈ្មោះ [redacted] NORA HENDRIK JACOBS (ប៊ិតណូរ៉ា ហេនឌ្រាត ចាក់កូប) ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ជាតិប៊ែលហ្ស៊ិច បានធ្វើដំណើរចេញពីផ្ទះដោយបើកបរម៉ូតូ ០១ គ្រឿងម៉ាក CPX ពណ៌ក្រហម ពាក់ស្លាកលេខ កណ្ដាល 1AE-9328 (ទិសដៅពីត្បូងទៅជើង) លុះមកដល់ចំណុចលើផ្លូវបេតុ ស្ថិតនៅភូមិព្រែកហូរកើត១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ត្រូវបានរថយន្តដឹកដី (ធុនធ្ងន់) ០១ គ្រឿង ម៉ាក នីសាន់ ពណ៌ខៀវ គ្មានស្លាកលេខ បើកបរដោយឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង ភេទប្រុស អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ (ទិសដៅពីត្បូងទៅជើង) បើកមកបុកគៀជនរងគ្រោះពីក្រោយ ធ្វើឱ្យខ្ទាតម៉ូតូទៅខាងស្ដាំ ហើយជនរងគ្រោះក៏ធ្លូលចូលទៅក្រោមកង់រថយន្តដឹកដីខាងលើនោះ បណ្ដាលឱ្យកិនជនរងគ្រោះរងរបួសស្នាមជាទម្ងន់។ បន្ទាប់មក ជនបង្កឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង បានបើកបររថយន្តគេចចេញពីកន្លែងកើតហេតុបាត់ ចំណែកជនរងគ្រោះត្រូវបានក្រុមគ្រួសារបញ្ជូនទៅព្យាបាលរបួសនៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ និងបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យបាំងកកប្រទេសថៃ ប៉ុន្តែដោយស្ថានភាពរបួសរបស់ជនរងគ្រោះធ្ងន់ធ្ងរពេក ក៏បានបណ្ដាលឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ តែម្ដង។



Scanned with CamScanner

## ២.២. អំពីអង្គច្បាប់

យោងតាមមាត្រា ៨២ នៃច្បាប់ចរាចរណ៍ផ្លូវគោកចែងថា "ជនណាប្រើប្រាស់ដោយគ្មានបណ្ណសម្គាល់រថយន្ត ឬគ្មានស្លាកលេខសម្គាល់រថយន្ត ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។ អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ថ្ងៃទៅ ០១ (មួយ) ខែ និងពិន័យជាប្រាក់ពី ៤០០ ០០០ (បួនសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចមកហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀតក្នុងកំឡុងពេល ០៦ (ប្រាំមួយ) ខែ ទៅ ០២ (ពីរ) ឆ្នាំ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន។ បទបញ្ញត្តិកថាខណ្ឌទី២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះអ្នកបើកបរទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត។" និងយោងតាមកថាខណ្ឌ ១ នៃមាត្រា ៨៥ នៃច្បាប់ចរាចរណ៍ផ្លូវគោកចែងថា "ជនណាបើកបរដោយធ្វេសប្រហែស ធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទបញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឱ្យស្លាប់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ទៅ ០៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល និងអាចត្រូវផ្តន្ទាទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។"

## ៣.៣.សេចក្តីសន្និដ្ឋាន

ដោយយោងតាមចម្លើយរបស់សាក្សីដែលបាននៅកន្លែងកើតហេតុឈ្មោះ [redacted] ស្រីហៀក និង [redacted] ហ៊ុន និងចម្លើយរបស់សាក្សីផ្សេងទៀតដែលបានដឹងឮរឿងហេតុបានរៀបរាប់ឱ្យដឹងថា ខណៈពេលដែលពួកគាត់កំពុងឈរទិញម្ហូបនៅតូបលក់ម្ហូបក្បែរកន្លែងកើតហេតុ ពួកគាត់បានឃើញជនបរទេសម្នាក់(ជនរងគ្រោះ) បានជិះម៉ូតូពណ៌ក្រហមទិសដៅពីត្បូង ទៅជើង ហើយឡានដឹកដីដែលបានបង្កហេតុបានបើកមកពីក្រោយកៀរម៉ូតូរបស់ជនរងគ្រោះដួលត្រឡប់ត្រឡិន ដោយម៉ូតូខ្ទាតចេញទៅខាងស្តាំដៃ ចំណែកមនុស្សត្រូវឡានបង្ករហេតុអូសប្រហែល ២០ (ម្ភៃ)ម៉ែត្រ ចូលក្រោមកង់ឡានកិន ចំពាក់កណ្តាលខ្លុំត្រង់ចង្កេះលាន់លឺសូរផ្ទុង បណ្តាលឱ្យជនរងគ្រោះដេកស្តូកស្តឹង។ ចំណែកឯឡានបង្កហេតុវិញបាន បើកទៅមុខទៀតបានចំងាយប្រហែល ១០ (ដប់)ម៉ែត្រពីជនរងគ្រោះទើបឈប់ ហើយជនសង្ស័យ ([redacted] សំណាង) ក៏ចុះមកមើលព្រមទាំងប្រពន្ធរបស់ជនសង្ស័យក៏ចុះមកមើលជាមួយជនសង្ស័យដែរ។ រួចមកជនសង្ស័យក៏បានទៅអូសជនរងគ្រោះមកដាក់នៅចិញ្ចើមផ្លូវបេតុងពីខាងលិចជិតផុងកាហ្វេ និងបានបណ្តើរម៉ូតូរបស់ជនរងគ្រោះពីចិញ្ចើមផ្លូវខាងកើត ទៅទុកនៅចិញ្ចើមផ្លូវពីខាងលិចវិញ ហើយជនសង្ស័យក៏បានបើកឡានបង្កហេតុចាកចេញពីកន្លែងកើតហេតុបាត់ទៅ។ បន្ថែមពីលើនេះទៅទៀត យោងតាមស្ថានភាពដំបូងរបស់ជនរងគ្រោះ និងយោងតាមការធ្វើកោសលវិច្ច័យរបស់មន្ទីរពេទ្យកម្ពុជា និងថៃ អ្នកឯកទេសកោសលវិច្ច័យគឺវេជ្ជបណ្ឌិត Wouter DEN BOGNERT បានធ្វើការវិភាគដោយផ្អែកទៅលើមូលដ្ឋានរបាយការណ៍វេជ្ជសាស្ត្រ និងរូបថតដែលមាន បានធ្វើការសន្និដ្ឋានថាស្ថានភាពរបួសដំបូងរបស់ជនរងគ្រោះនៅត្រង់ត្រគាងចំហៀងខាងស្តាំ គឺមិនមែនបណ្តាលមកពីការដួលធ្លាក់ពីលើម៉ូតូតែម្យ៉ាងនោះទេ ប៉ុន្តែគឺអាចបណ្តាលមកពីមានភាគីទីបីបុក រួចបើកកិនពីលើផងដែរទើបស្ថានភាពរបួសក្លាយទៅជាធ្ងន់ធ្ងររហូតដល់បែកគ្រៀងក្នុង និងបាក់ឆ្អឹងត្រគាកខ្លាំងយ៉ាងនេះ។ យើងកត់សម្គាល់ឃើញថាចម្លើយរបស់សាក្សីឈ្មោះ



Scanned with CamScanner

[redacted] ស្រីហៀក និង [redacted] ហ៊ុន និងចម្លើយរបស់សាក្សីផ្សេងទៀតដែលបានដឹងឮរឿងហេតុ គឺស៊ីសង្វាក់ទៅនឹងរបាយការណ៍កោសលវិច្ច័យរបស់អ្នកឯកទេសកោសលវិច្ច័យគឺវេជ្ជបណ្ឌិត Wouter DEN BOGAERT ដែលត្រូវបានស្នើឡើងដោយចៅក្រមថ្នាក់ក្រោមរបស់សហព័ន្ធប៊ែលហ្ស៊ិក។ ជាងនេះទៅទៀត យើងអាចពិចារណាអំពីការអះអាងរបស់ជនសង្ស័យដែលថា ជនរងគ្រោះជិះម៉ូតូដួលដោយខ្លួនឯង ដោយជនសង្ស័យពុំបានបើកឡានកៀរនិងកិនទៅលើជនរងគ្រោះនោះទេ ទៅនឹងស្ថានភាពនៃរបួសដ៏ធ្ងន់ធ្ងររបស់ជនរងគ្រោះ។ ត្រឹមតែជិះម៉ូតូដួលដោយខ្លួនឯងដោយពុំមានអ្វីមកសង្កត់ ឬកិនពីលើខ្លួនរបស់ជនរងគ្រោះ តើរបួសរបស់ជនរងគ្រោះអាចឈានទៅដល់ការបែកគ្រឿងក្នុង និងបាក់ត្រគាកដូចនេះដែរឬទេ? បើយើងក្រឡេកទៅមើលពីស្នាមចាប់ហ្វ្រាំងអូសរបស់ម៉ូតូទៅកន្លែងម៉ូតូដួល នៅកន្លែងកើតហេតុដែលបានរៀបរាប់នៅក្នុងរបាយការណ៍សំយោគស្តីពីករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកលេខ ០៥៩ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅបានរៀបរាប់ថា នៅកន្លែងកើតហេតុមានស្នាមចាប់ហ្វ្រាំងអូសរបស់ម៉ូតូប្រវែង ១៤,៥០ (ដប់បួនក្បៀសហាសិប) ម៉ែត្រ។ បើសិនជាជនរងគ្រោះជិះម៉ូតូដួលដោយខ្លួនឯង តើអាចទេដែលដួលហើយអូសរហូតទៅដល់ប្រវែង ១៤,៥០ (ដប់បួនក្បៀសហាសិប) ម៉ែត្រនោះ ទាំងដែលជនរងគ្រោះបើកម៉ូតូយឺតៗនោះ។ យោងតាមអង្គហេតុ អង្គច្បាប់ និងភស្តុតាងដូចដែលបានលើកឡើងខាងលើ អាចបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាជនរងគ្រោះឈ្មោះ [redacted] NORA HENDRIK JACOBS ([redacted] ហេនដ្រាត ចាក់កូប) រងរបួសរហូតដល់បាត់បង់ជីវិតនោះ គឺបង្កឡើងដោយសារតែការបើកបររថយន្តដោយការធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នរបស់ជនសង្ស័យឈ្មោះ សយ សំណាង ហៅ សាន សំណាង ទើបកៀរជនរងគ្រោះឱ្យដួលចូលក្រោមរថយន្តរបស់ខ្លួន ហើយក៏កិនពីលើជនរងគ្រោះធ្វើឱ្យបែកគ្រឿងក្នុង និងបាក់ឆ្អឹងត្រគាកយ៉ាងធ្ងន់ធ្ងររហូតដល់បាត់បង់ជីវិតដូច្នេះ ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារក្តីឱ្យ **យ៉ាវ ស៊ីថាន** ដែលត្រូវជាសហព័ទ្ធរបស់ជនរងគ្រោះ ខ្ញុំបាទសូមសំណូមពរឱ្យឯកឧត្តមប្រធានមេត្តាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ សយ សំណាង ហៅ សាន សំណាង ដាក់ពន្ធនាគារទៅតាមច្បាប់រដ្ឋដែលមានចែងជាធរមាន។

**៣. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពីបានស្តាប់ការសាកសួរដេញដោល ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ភស្តុតាងក្នុងសំណុំរឿងពិតជាស៊ីសង្វាក់គ្នានៅក្នុងសំណុំរឿង ហើយជនជាប់ចោទបានបើកបរគ្មានប័ណ្ណបើកបរ គ្មានស្លាកលេខសម្គាល់យានយន្ត។ ចំពោះការពិនិត្យភស្តុតាងស៊ីសង្វាក់ទៅនឹងមន្ទីរពេទ្យ ហើយស៊ីសង្វាក់ទៅនឹងរបួសរបស់ជនរងគ្រោះ ចំណែករបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ជាភស្តុតាងបន្ទាល់តែប៉ុណ្ណោះ។ ហេតុនេះស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមកម្រិតទោសដើម្បីកុំឱ្យមានបទល្មើសកើតឡើងតាមផងវិថីទៀត។



Scanned with CamScanner

**៤. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] សន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោល និងរបាយការណ៍របស់ខាងមន្ទីរពេទ្យជាការបង្ហាញពីមរណភាព មិនបានបង្ហាញពីព្រឹត្តការណ៍ និងសកម្មភាព ប្រសិនបើហេតុការណ៍ផ្សេងទៀតក៏ទទួលរងសំពាធដូចដែរ ឧទាហរណ៍ ការខ្ទប់នឹងទូរការហៀ សរសរផ្សេង ពុំមានរបាយការណ៍ថាឡានកិនឡើយ។ តាមចម្លើយសាក្សីឈ្មោះ [redacted] ស្រីហៀក គឺមានតែស្នាមដី មិនមានកង់ឡាន។ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ថាការជិះលឿន ចាប់ហ្វ្រាំងលឿន គឺកំណត់ហេតុជាបន្ទាល់បាន រហូតដល់មានភស្តុតាងផ្ទុយ។ ចម្លើយរបស់ឈ្មោះ [redacted] ស្រីហៀក ផ្ទុយនឹងចម្លើយនៅអយ្យការ។ ប្រសិនបើកិនប្រាកដជាដាច់តាមរបាយការណ៍ផ្សេងៗគឺផ្លូវតូច ផ្លូវមានកម្មវិធី ប្រាកដជាបុករោង។ តាមឆ្លើយថា មានតែឡានរបស់ឈ្មោះ [redacted] សំណាង តែឈ្មោះ សុខហ៊ែរ ថាមានឡានតូច១ទៀត បន្ទាប់ពីមុខកូនឡាមានឡានដឹកឈើទៀត មិនមែនតែឡាន ១ ទេ សម្បីតែសាក្សីក្នុងសំណុំរឿងសុទ្ធតែមិនបានឃើញថាកិនពីឡានខាងឆ្វេង ឬខាងស្តាំ ឬយ៉ាងណា។ ចម្លើយសាក្សីមានជនរងគ្រោះស្លាប់ម្លូលលើថ្នល់ ដោយមិនដឹងមូលហេតុ។ ការចោទប្រកាន់កូនក្តីខ្ញុំបាទមិនពិតទេ គាត់គ្រាន់តែចុះជួយជនរងគ្រោះប៉ុណ្ណោះ គាត់មានចិត្តចង់ជួយ តែត្រូវទទួលរងនូវទោសទណ្ឌទៅវិញ។ រាល់ភស្តុតាងទាំងអស់ពុំអាចបញ្ជាក់ថាកូនក្តីខ្ញុំបាទប្រព្រឹត្តបទល្មើស។ ហេតុនេះមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ ហេតុនេះស្នើសុំចៅក្រមសម្រេចឱ្យកូនក្តីខ្ញុំបាទរួចខ្លួន។

*- ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **៥៥៦ អ.ក** ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ៥៤ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើមកជំនុំជម្រះពីបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាម



Scanned with CamScanner

មាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **សំណាង**៕

**គ. អំពី ពិរុទ្ធភាព**

**១.** តាមចម្លើយជនជាប់ចោទ នៅក្នុងកិច្ចពិភាក្សាដេញដោល សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានបង្ហាញថា អង្គហេតុហេតុដែលប្ដឹងមកតុលាការ គឺជាអង្គហេតុពិតប្រាកដ ដែលបានកើតឡើង។ តុលាការយល់ឃើញថាដោយសារ តែអង្គហេតុដែលប្ដឹងមកតុលាការនេះ កើតមានឡើង ដែលជាហេតុនាំឱ្យតុលាការទទួលស្គាល់នូវការកើតនូវអង្គហេតុខាងលើនេះ តុលាការនឹងបន្តពិនិត្យលើបទចោទប្រកាន់ និងអង្គហេតុ តាមរយៈការវាយតម្លៃ និងផ្ទៀងផ្ទាត់ ថាតើអង្គហេតុដែលប្ដឹងមកតុលាការនោះ គឺជាបទល្មើសព្រហ្មទណ្ឌដែរឬទេ។

**២.** តាមភស្តុតាងក្នុងសំណុំរឿងដែលរួមមាន៖

**២.១.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សំណាង** នៅចំពោះមុខតំណាងអយ្យការ ដែលបានឆ្លើយថា *"នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ខ្ញុំបើកឡានដឹកដី ០១ គ្រឿងម៉ាក ទីសាន់ ពណ៌ខៀវ អត់ពន្ធ គ្មានស្លាកលេខ ទម្ងន់ ០៨ តោន មកពីចាក់ដីវិញ ទិសដៅពីត្បូងទៅជើង មកដល់ត្រង់ចំណុចផ្លូវបេតុងមួយកន្លែង ស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល* ***ខណៈពេលខ្ញុំកំពុងបើកបរឡានសុខៗ ស្រាប់តែលឺស្នូរផាំងពេលនោះខ្ញុំឈប់ឡាន*** *រួចចុះទៅមើល ឃើញម៉ូតូ០១ គ្រឿងមិនចាំម៉ាក ពណ៌ក្រហម ទូលក់ការហ្វេ និងឃើញជនរងគ្រោះជនបរទេសជាអ្នកបើកបរម៉ូតូ ឃើញដូច្នេះខ្ញុំបានទៅជួយគ្រា និងដោះមួកសុវត្ថិភាពគាត់ចេញ ហើយជនរងគ្រោះបានហាមាត់តិចៗ តែខ្ញុំស្ដាប់ភាសាគាត់មិនបាន ខ្ញុំក៏បន្តបើកឡានទៅដឹកដីជាធម្មតាវិញ។ ខ្ញុំមិនដឹងថា ជនរងគ្រោះរងគ្រោះថ្នាក់មកពីអ្វីនោះទេ ព្រោះក្នុង* ***ពេលកើតហេតុ ខ្ញុំបើកបរឡានសុខៗ ស្រាប់តែឮសម្លេងប្រាវ ខ្ញុំក៏បានឈប់ឡានប្រហែល ១០ ម៉ែត្រ ពីកន្លែងកើតហេតុ រួចក៏ចុះទៅមើល*** *តែខ្ញុំមិនបានសួរនាំអ្នកនៅភ្នំនោះថា ជនរងគ្រោះរងគ្រោះថ្នាក់មកពីអ្វីទេ។"*

**២.២.** តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីហៀក ដែលបានឆ្លើយថា *"នៅថ្ងៃកើតហេតុ ខ្ញុំជិះម៉ូតូពីខាងជើងមកផ្សារជាមួយបងស្រី ដោយឃើញជនរងគ្រោះដេកស្តូកស្តឹងនៅផ្លូវ ដោយឃើញថា គាបារាំងត្រូវដេកនៅផ្លូវ ហើយឃើញឡានរបស់ឈ្មោះ [redacted] សំណាង នៅពីមុខ។ ជនរងគ្រោះហូរឈាមត្រង់ត្រគាក ដោយគេនាំគ្នាចូលលើកគាត់ ដោយឈ្មោះ [redacted] សំណាង និងប្រពន្ធគាត់ចូលទៅលើកជនរងគ្រោះ។* ***ម៉ូតូរបស់ជនរងគ្រោះត្រឡប់ត្រឡិន បែរក្បាលទៅខាងលិច ដោយម៉ូតូនោះមានសភាពខ្ទាត់ចេញ ខ្ញុំយល់ថា គ្រោះថ្នាក់ចរាចរណ៍ តែមិនមែនជិះទៅបុកដើមឈើ និងបង្គោលភ្លើងទេ ម៉ូតូខ្ទាត់ទៅខាងកៀន មនុស្សនៅកណ្ដាលថ្នល់។*** *ឈាមជនរងគ្រោះ ហូរឈាមតាមត្រគាក នោះអាវគាត់សុទ្ធតែដី ហូរឈាមត្រង់ត្រគាក ខ្ញុំឃើញហូរឈាមផ្នែកខាងក្រោយខ្នង តែមិនមានបែកក្បាល។ ពេលលើកគាត់ឡើង ជនរងគ្រោះសន្លប់បាត់ហើយក៏នាំគ្នាលើកយកមកខ្លាចគាត់ក្ដៅ។* ***នៅកន្លែងកើតហេតុមានតែឡានឈ្មោះ [redacted] សំណាង មិនមានឡានផ្សេងទៀតទេ ឡាននោះពុំមានដឹកដីទេ ពុំមានស្លាកលេខផងដែរ។*** *ខ្ញុំសូមបញ្ជាក់ថា ពេលខ្ញុំទៅដល់ឈរមើលឃើញជនរងគ្រោះទើបឃើញឈ្មោះ*



Scanned with CamScanner

[redacted] សំណាង និងប្រពន្ធចុះមក។ គ្រាប់តែមានប៉ូលីសជិះកាត់ស្ទះចរាចរណ៍ ប៉ូលីសក៏សួរឈ្មោះ [redacted] សំណាង ថា "មានរឿងអី" ទើបឈ្មោះ [redacted] សំណាង ថា "មិនដឹងដែរ ពេលបើកឡានសុខៗស្រាប់តែលើស្ទួរផ្លូវ"។ ពេលខ្ញុំមកដល់កន្លែងកើតហេតុ ទល់មុខកន្លែងកើតហេតុប្រាប់ថា "ឡានដឹកដីកិនគាត់"។ ជាអ្នកផ្សេងនិយាយថា "កុំចេះតែថាឡានកិន" អ្នកនិយាយនោះជាបងប្អូនឈ្មោះ [redacted] សំណាង។ ចំណែកឈ្មោះ [redacted] ស្រីហ៊ិន ជាបងស្រីខ្ញុំ។"

២.៣. ចម្លើយសាក្សីឈ្មោះ [redacted] ស្រីហ៊ិន ដែលបានឆ្លើយថា "កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០២១ ជាថ្ងៃរៀបការចៅរបស់លោកប្រធានភូមិព្រែកហូរលិចឈ្មោះ ណាង នៅវេលាម៉ោង ១០ ព្រឹក ខ្ញុំ និងប្អូនស្រីឈ្មោះ [redacted] ស្រីហៀក អាយុ ៣០ ឆ្នាំ បាននាំគ្នាជិះម៉ូតូ១គ្រឿង ម៉ាក HONDA DREAM ស៊េរី២០១៥ ពណ៌ខ្មៅ មិនចាំពាក់ស្លាកលេខ ចេញពីផ្ទះទៅទិញម្ហូបនៅផ្ទះយាយហ៊ោយ ឆ្លងកាត់តាមផ្លូវបេ៉តុងមួយកន្លែង ដល់ចំណុចផ្ទះយាយហ៊ោយ ស្ថិតនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានឃើញមានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងនៅទល់មុខផ្ទះយាយហ៊ោយ តែនាងខ្ញុំមិនបានឃើញហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នោះផ្ទាល់ទេ ពេលនាងខ្ញុំទៅដល់ករណីគ្រោះថ្នាក់ចរាចរណ៍នោះបានកើតឡើងរួចទៅហើយ ដោយនាងខ្ញុំឃើញជនបរទេសម្នាក់ មិនស្គាល់ឈ្មោះ ភេទប្រុស មានស្លាយសាក់កាដូពីក្រោយ ដេកដួលនៅកៀនកង់ឡានដឹកដី១គ្រឿង ១ម្ភៃ ៥ តោន ពណ៌ខៀវ គ្មានស្លាក លេខ ដេកដួលក្បែរកងឡានខាងក្រោយនៅខាងលិច ឡានក្បាលទៅត្បូង ហើយពេលនោះឡានដឹកដីនោះបាន បើកទៅមុខបន្តទៀតប្រហែលជា ១០ ម៉ែត្រ ទើបឈប់ ឃើញម្ចាស់ឡានដឹងដីនោះ គាត់ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុប្រហែល ៤០ ឆ្នាំ ជាកូនរបស់លោកស្រីមេភូមិព្រែកហូរកើត២ [redacted] សឿន បានចុះមកមើលនឹង លើកជនបរទេសជាជនរងគ្រោះចេញពីកន្លែងកើតហេតុ ដោយមានឈ្មោះ [redacted] សំណាង និងជាងឡានម្នាក់ ឈ្មោះ ម៉ាប់ បានលើកជនរងគ្រោះរំកិលចេញពីកន្លែងកើតហេតុពីព្រោះមុនដំបូងជនរងគ្រោះដេកដួលបែរ ក្បាលទៅជើង ហើយត្រូវឈ្មោះ [redacted] សំណាង និង ឈ្មោះ ម៉ាប់ បានលើករំកិលជនរងគ្រោះចេញពីកន្លែងកើតហេតុបន្តិច ដាក់ឱ្យជនរងគ្រោះដេកបែរក្បាលទៅត្បូងវិញ។ ខ្ញុំចាំថា ម៉ូតូជនរងគ្រោះ មិនចាំម៉ាក ពណ៌ ក្រហម ឃើញដួលនៅខាងលិចផ្លូវ កៀនតូបកាហ្វេ។ នៅពេលខ្ញុំឈរមើលនោះខ្ញុំឮឈ្មោះ [redacted] សំណាង និយាយថា "គាត់បើកទ្វារ ឡានចុះមក ឮស្នូរតែភ្លូស ដោយនាងខ្ញុំឮឈ្មោះ [redacted] សំណាង និយាយតែប៉ុណ្ណឹង។ បន្ទាប់មកនៅពេលឈ្មោះ [redacted] សំណាង កំពុងតែឈរនៅកន្លែងកើតហេតុនោះខ្ញុំឃើញអតីតមេប៉ុស្តិ៍ព្រែកហូរឈ្មោះ ក្រាច់ បច្ចុប្បន្នគាត់ជាមេប៉ុស្តិ៍ខ្ទបរ៉ែក បានចង្អុលប្រាប់ឱ្យអ្នកបើកឡានដឹកដីឈ្មោះ [redacted] សំណាង បើកឡានចេញទៅ ហើយឈ្មោះ [redacted] សំណាង ក៏បើកឡានចេញទៅបាត់ទៅ។ នាងខ្ញុំឮអ្នកភូមិដែលឈរមើលករណីគ្រោះថ្នាក់ចរាចរណ៍នៅកន្លែងកើតហេតុនោះ ពួកគាត់និយាយថា ករណីគ្រោះថ្នាក់ចរាចរណ៍ គឺបង្កឡើងរវាងឡានដឹកដី បុកគ្នាជាមួយម៉ូតូជនរងគ្រោះ ហើយនាងខ្ញុំបានឮតែប៉ុណ្ណឹង មិនដឹងថា ខាងណាខុសខាងណាត្រូវនោះទេ។ នៅកន្លែងកើតហេតុ ខ្ញុំឃើញមានតែឡានដឹកដីមួយគ្រឿងរបស់ឈ្មោះ [redacted] សំណាង ប៉ុណ្ណោះ ពុំឃើញមានឡានផ្សេងទៀតនៅពីមុខ ឬពីក្រោយកន្លែងកើតហេតុនោះទេ ចំណែកជនរងគ្រោះ ខ្ញុំឃើញគាត់ស្លៀកខោក្រណាត់ជើងវែង ពណ៌ខ្មៅ ពាក់អាវសាច់ក្រណាត់ដៃខ្លី ពណ៌ខៀវ ស្រាវៀងពណ៌អាវខោ ប៊ិយ ហើយពេលឈ្មោះ [redacted] សំណាង និងឈ្មោះ ម៉ាប់ លើកជនរងគ្រោះ នាងខ្ញុំឃើញជនរង



Scanned with CamScanner

*គ្រោះមានឈាម ហូរដូចគេអារកមាន់អញ្ចឹងចេញពីត្រចៀកគាត់ និងឃើញកែងដៃជនរងគ្រោះរលាតចេញឈាម ចំណែកកន្លែងផ្សេងទៀតខាងខ្ញុំមិនបានឃើញទេ ព្រោះគេមិនដោះខោអាវជនរងគ្រោះមើលនោះទេ។"*

**២.៤.** លិខិតឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ស្រីហ៊ិន ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១, លិខិតឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ស្រីហៀក។

**២.៥.** របាយការណ៍សង្ខេបមុនសម្រេចឱ្យចាកចេញចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ របស់មន្ទីរពេទ្យបាងកក បង្ហាញថា ជនរងគ្រោះឈ្មោះ [redacted] NORA HENDRIK JACOBS (**ប៊ីតណូរ៉ា ហេនគ្រាត ចាក់កូប**) ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ញាតិប៊ែលហ្ស៊ិក មាន (១) រោគវិនិច្ឆ័យគោល គឺបានបាក់ឆ្អឹងត្រគាក រួមទាំងមានការផ្ទុះធ្លាយលើទ្វារនោម មានរងរបួសធ្ងន់ធ្ងរនៅលើភ្លៅខាងស្តាំ និងសរសៃឈាមនៃឆ្អឹងភ្លៅ (២) រោគវិនិច្ឆ័យមធ្យម គឺស្រោមសួតទាំងសងខាង និងសួតរងរបួសជាំ បាក់ឆ្អឹងជំនីផ្នែកខាងស្តាំជាច្រើនកន្លែង រងរបួសទៅលើខួរក្បាលផ្នែកសរសៃប្រសាទចម្លងចរន្ត ..... និង (៥) មូលហេតុរបួសខាងក្រៅ គឺរបួសធ្ងន់ដោយសារគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្ត។

**២.៦.** របាយការណ៍របស់សាកលវិទ្យាល័យមន្ទីរពេទ្យ LEUVEN ផ្នែកនីតិសាស្ត្រចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ បង្ហាញថា ជនរងគ្រោះឈ្មោះ [redacted] HENDRIK JACOBS (**ប៊ីតណូរ៉ា ហេនគ្រាត ចាក់កូប**) ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ញាតិប៊ែលហ្ស៊ិក គឺបានប៉ះទង្គិចដោយកម្លាំងខ្លាំងដែល (សូម្បីតែក្នុងល្បឿនលឿន) មិនអាចពន្យល់បានថា គ្រាន់តែដួលជាមួយម៉ូតូនោះទេ។ ការចូលរួមរបស់ភាគីទីបី ត្រូវតែយកមកពិចារណា៖ ការបុកគ្នា ឬការកិនពីលើ។

**២.៧.** តាមរបាយការណ៍របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅលេខ ០៥៩ របក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ បង្ហាញថា ករណីគ្រោះថ្នាក់ចរាចរណ៍នេះបណ្តាលមកពីអ្នកបើកបរម៉ូតូម៉ាក HONDA PCX ពណ៌ក្រហម ពាក់ស្លាកលេខ កណ្តាល 1AC-9828 បើកបរមានល្បឿនលឿន ប្រជែងជ្រុលចង្កូតមកឆ្វេងដៃចាប់ប្រៀងបង្ខំដួលអូសទាំងម៉ូតូ និងមនុស្សតែម្តង។

**២.៨.** តាមភស្តុតាងខាងលើ តុលាការបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សំណាង** បានបំពេញធាតុសត្យានុម័តនៃបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ព្រោះជនជាប់ចោទបានសារភាពថា បានបើកឡានដឹកដី ០១ គ្រឿងម៉ាក ទីសាន់ ពណ៌ខៀវ អត់ពន្ធ គ្មានស្លាកលេខ ទម្ងន់ ០៨ តោន និងបានបំពេញធាតុសត្យានុម័តនៃបទ **បើកបរដោយធ្វេសប្រហែសធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍ដោយមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ព្រោះចម្លើយរបស់ជនជាប់ចោទ ចម្លើយសាក្សី និងរបាយការណ៍របស់អ្នកជំនាញ បង្ហាញថា ជនរងគ្រោះបានស្លាប់ដោយសាររបួសធ្ងន់ធ្ងរ ដែលកើតឡើងពីបានបុកគ្នា ឬការកិនពីលើដោយរថយន្ត ហើយស្របពេលដែលជនជាប់ចោទក៏បានឆ្លើយសារភាពថា ខ្លួនលឺសម្លេងប្រាវនៅពេលខ្លួនកំពុងបើកបរ ដោយឡែកចម្លើយរបស់



Scanned with CamScanner

សាក្សីបង្ហាញថា សាក្សីបានឃើញជនរងគ្រោះនៅដេកក្បែរកង់រថយន្ត។ នេះអាចឱ្យតុលាការធ្វើការសន្និដ្ឋានជារួមថា ជនជាប់ចោទពិតបានបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ និងបានរត់គេចពីកន្លែងកើតហេតុដោយមិនទទួលខុសត្រូវ ដែលនេះជាស្ថានទម្ងន់តាមមាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ដោយឡែក របាយការណ៍លេខ ០៥៩ របក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ជារបាយការណ៍ដែលពុំមានភាពស៊ីសង្វាក់ទៅនឹងស្ថានភាពនៃរបួសរបស់ជនរងគ្រោះ និងពុំមានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ទីរពេទ្យនោះទេ។ បន្ថែមពីនេះ របាយការណ៍នេះត្រូវបានធ្វើឡើងក្រោយពេលកើតហេតុ រហូតដល់ទៅ ១២ (ដប់ពីរ) ថ្ងៃ ហើយដែលការវាស់វែងផ្សេងៗ ត្រូវបានធ្វើឡើង ក្រោយពេលកន្លែងកើតហេតុត្រូវបានបំផ្លាញ ឬមានភាពប្រែប្រួលទៅហើយ។ ហេតុនេះ តុលាការចាត់ទុកថា របាយការណ៍នេះពុំមានភាពត្រឹមត្រូវ។

៣. តាមសំអាងហេតុចំណុចទី១ ដល់ទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង បានបំពេញធាតុអត្តនោម័តនៃបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទបានបើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបានបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ។

៤. តាមសំអាងហេតុចំណុចទី២ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង បានបំពេញធាតុផ្សំនៃបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត តាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង បានបំពេញធាតុផ្សំនៃបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថ**



Scanned with CamScanner

**យន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបទ បើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង មានពិរុទ្ធភាពពីបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបទ បើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារ តាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **សំណាង ចំនួន ០៣ (បី) ឆ្នាំ ០៦ (ប្រាំមួយ) ខែ** ពីបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែសខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ព្រោះអំពើរបស់ជនជាប់ចោទនេះ បានបណ្ដាលឱ្យមានការស្លាប់ជនរងគ្រោះ ហើយមិនទទួលខុសត្រូវចំពោះរបស់ខ្លួន។ **អំពើនេះបានបណ្ដាលឱ្យមានការប៉ះពាល់ដល់អាយុជីវិត ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខសង្គមយ៉ាងធ្ងន់ធ្ងរ ហេតុនេះ ការសម្រេចទណ្ឌកម្មព្រហ្មទណ្ឌខាងលើនេះ តុលាការយល់ឃើញថា មានភាពសមល្មមទៅនឹងអំពើរបស់ជនជាប់ចោទ៕**

**ឆ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។



Scanned with CamScanner

## ផ. អំពី សេចក្ដីសម្រេចពិសេសលើការបង្គាប់ឱ្យចាប់ខ្លួន

តាមរយៈភស្តុតាងដែលមានក្នុងសំណុំរឿង និងតាមរយៈកិច្ចពិភាក្សាដេញដោលក្នុងសវនាការ បង្ហាញថា ផ្អែកតាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស និងតាមសំអាងហេតុចំណុច ឆ (អំពី របបនៃការប្រកាសទោស) និងតាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៦៣៦ ដកបចខ២១ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល តុលាការនឹងសម្រេចចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សំណាង តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៕

## ឈ. អំពី បណ្ដឹងរដ្ឋប្បវេណី

១. ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] សំណាង ត្រូវបានរកឃើញថា មានពិរុទ្ធភាពលើអង្គហេតុដែលបានប្ដឹងមកតុលាការ ហេតុដូច្នេះ តុលាការនឹងសម្រេចពិចារណាអំពីសំណងនៃការខូចខាត និងសំណងជំងឺចិត្ត ប្រសិនបើមានការទាមទារ។

២. ផ្អែកតាមភស្តុតាងដែលមានក្នុងសំណុំរឿង តុលាការយល់ឃើញថា បណ្ដឹងឈ្មោះ [redacted] ស៊ីថាន ត្រូវបានធ្វើឡើងស្របទៅនឹងមាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបណ្ដឹងនេះ បានបំពេញលក្ខខណ្ឌនៃមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះ តុលាការទទួលស្គាល់ឈ្មោះ [redacted] ស៊ីថាន ជាដើមបណ្ដឹងរដ្ឋប្បវេណី។

៣. ដោយហេតុថា តុលាការបានសម្រេចទទួលស្គាល់ឈ្មោះ [redacted] **ស៊ីថាន** គឺជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយដោយផ្អែកលើភស្តុតាងដែលអាចបង្ហាញអំពីព្យសនៈកម្មខាងសម្ភារៈ ខាងរូបកាយ ខាងផ្លូវចិត្ត តុលាការនឹងសម្រេចបង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សំណាង** សងសំណងនៃការខូចខាត សំណងជំងឺចិត្ត មួយផ្នែកចំនួន **៥០០.០០០ (ហាសិបម៉ឺន) ដុល្លារអាមេរិក** ព្រោះជនរងគ្រោះ គឺជាវេជ្ជបណ្ឌិត ហើយជាបុគ្គលដែលស្ថិតនៅក្នុងភាពដែលនៅមានសក្ដានុពលក្នុងវិជ្ជាជីវៈជាគ្រូពេទ្យ។ ម្យ៉ាងវិញទៀត ជីវិត គឺមិនអាចកាត់ថ្លៃបាន។ ហេតុនេះ តុលាការសម្រេចតាមការទាមទារមួយផ្នែកតាមចំនួនខាងលើនេះ ហើយការទាមទារលើសពីនេះ ត្រូវបានច្រានចោល។

## សេចក្ដីសម្រេច

ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៦៧ (អាយុ ៥៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ៖

១. ពីបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់** ប្រព្រឹត្តនៅភូមិព្រែកហូរលិច ១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

២. ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ហើយត្រូវប្ដូរបទចោទប្រកាន់លើជនជាប់ចោទពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីចរាចរណ៍



Scanned with CamScanner

ផ្លូវគោក ទៅជាបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១៕

ខ. ផ្ដន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ **សយ សំណាង** ភេទប្រុស កើតឆ្នាំ១៩៦៧ (អាយុ ៥៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន ០៣ (បី) ឆ្នាំ ០៦ (ប្រាំមួយ) ខែ ពីបទ **បើកបរដោយគ្មានប័ណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់ និងបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជារមិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៨២ មាត្រា ៨៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

គ. បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៦៧ (អាយុ ៥៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ឃ. ទទួលស្គាល់ឈ្មោះ [redacted] **ស៊ីថាន** ភេទស្រី កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៨ (អាយុ ៤៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ជាដើមបណ្ដឹងរដ្ឋប្បវេណី និងបង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៦៧ (អាយុ ៥៤ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ សងសំណងនៃការខូចខាត និងសំណងជំងឺចិត្ត ចំនួន **៥០.០០០ (ហាសិបម៉ឺន) ដុល្លារអាមេរិក** ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីថាន**។ ច្រានចោលការទាមទារលើសពីនេះ។

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈនៅចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី/ ចាត់ទុកជាចំពោះមុខជនជាប់ចោទ។*

*សាលក្រមព្រហ្មទណ្ឌនេះ ប្រកាសជាសាធារណៈ នៅថ្ងៃ អង្គារ ១០ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង ០០ នាទី នៅសាលសវនាការលេខ ០៥។*

*ភាគីដែលមានបំណងធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើតាមការកំណត់របស់ច្បាប់។*

**ក្រឡាបញ្ជីសវនាការ** — **ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted] — **ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ អង្គារ ១០ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner